# ព្រៃ កោងកាង

## នៅព្រះរាជាណាចក្រកម្ពុជា

## ខែសីហា ឆ្នាំ២០១២

**អនុក្រុមស្រាវជ្រាវ សេដ្ឋកិច្ចកសិកម្ម**

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

# មាតិកា


បញ្ជីតារាង........................................................................................................ III

I.សេចក្ដីផ្ដើម........................................................................................................ 1

II.ប្រវត្តិនៃការករកើត និងតំបន់ដែលមានព្រៃកោងកាងដុះ នៅក្នុងពិភពលោក.......... 1

ក. ប្រវត្តិនៃការករកើត........................................................................................ 1

ខ. តំបន់ដែលមានព្រៃកោងកាងដុះ.................................................................... 2

III.ស្ថានភាពព្រៃកោងកាងនៅព្រះរាជាណាចក្រកម្ពុជា................................. 4

ក. ការពិពណ៌នាអំពីរុក្ខជាតិ ........................................................................ 7

ខ. ការពិពណ៌នាអំពីសត្វ............................................................................. 8

គ. ការពិពណ៌នាអំពីផ្កាថ្ម និងស្មៅសមុទ្រ.................................................... 8

IV.ការប្រើប្រាស់រុក្ខជាតិកោងកាង.......................................................... 9

១ . តម្លៃប្រើប្រាស់ផ្ទាល់............................................................................ 9

២ . តម្លៃប្រើប្រាស់មិនផ្ទាល់...................................................................... 11

៣ . តម្លៃប្រើប្រាស់ផ្សេងទៀត..................................................................... 13

V.ការគំរាមកំហែងលើរុក្ខជាតិកោងកាង.................................................. 14

VI.ហេតុដូចម្ដេចបានជាបញ្ហាគំរាមកំហែងនេះកើតឡើង................................ 17

ក.តម្រូវការលើអុស ធ្យូង និងផលិតផលព្រៃឈើផ្សេងទៀត...................................... 17

ខ.កង្វះខាតការសិក្សា និងការដាក់ពិន័យ................................................................ 18

គ.កង្វះការយល់ដឹង និងសម្បជញ្ញៈរបស់សហគមន៍មូលដ្ឋាន.................................. 18

ឃ.ការខិតខំប្រឹងប្រែងនៅក្នុងការកាត់បន្ថយការបំផ្លិចបំផ្លាញព្រៃកោងកាង.............. 18

VII.អនុសាសន៍............................................................................................ 19

VIII.សេចក្តីសន្និដ្ឋាន..................................................................................... 21

ឯកសារយោង.......................................................................................... 22

កិច្ចសម្ភាសន៍............................................................................................ 24

សេចក្តីបន្ថែម១: ប្រភេទឈើផកងកាងនៅព្រះរាជាណាចក្រកម្ពុជា...................... 25

សេចក្តីបន្ថែម២: ប្រភេទសត្វមួយចំនួននៅព្រះរាជណាចក្រកម្ពុជា....................... 27

# បញ្ជីតារាង

តារាង១.ផ្ទៃដីគ្របដណ្តប់ដោយព្រៃកោងកាង......................................................3
តារាង២. ផ្ទៃដីកោងកាងប៉ាន់ស្មាននៃ១៥ប្រទេសដែលមានតំបន់កោងកាងធំជាងគេ....3
តារាង៣. ផ្ទៃដីកោងកាងនៅប្រទេសកម្ពុជា..........................................................4
តារាង៤. ស្ថានភាពផ្ទៃដីកោងកាងតាមអំឡុងពេលផ្សេងៗ.......................................6

## I. សេចក្ដីផ្ដើម

ភាគខាងត្បូងនៃប្រទេសកម្ពុជា មានព្រំដែនជាប់ជាមួយនឹងឈូងសមុទ្រថៃ ដែល លាតសន្ធឹងប្រវែងជាង៤៣៥គីឡូម៉ែត្រ។ មួយភាគបីដំបូងនៃតំបន់ឆ្នេរ គិតចេញពីព្រំដែនថៃមក មានលក្ខណៈទាប ជាដីភក់ល្បាប់ និងសម្បូណ៌ទៅដោយរុក្ខជាតិ កោងកាង និង មានភូមិនេសាទតូចៗជាច្រើននៅក្នុងតំបន់នេះ។ មួយភាគបីបន្ទាប់នៃ តំបន់ឆ្នេរ សម្បូណ៌ទៅដោយថ្មខ្ពស់ទាប ច្រងេងច្រងាង មានច្រាំងចោតឆ្លាស់ជាមួយនឹងឆ្នេរខ្សាច់។ នៅ តំបន់នេះ ពោរពេញទៅដោយដើមស្នាយ (Casuarina equisetifolia) និងចំការដូង។ រីឯមួយ ភាគបីចុងក្រោយនៃតំបន់ឆ្នេរដែលជាប់ជាមួយនឹងឆ្នេររបស់ប្រទេសវៀតណាម មានលក្ខណៈទាប និងជានិច្ចជាកាលជាកន្លែងភក់ល្បាប់ គឺជាតំបន់ដែលរុក្ខជាតិកោងកាង មានសភាពនៅក្មេងខ្ចីនៅឡើយ ( Tan Kim Huon, 1963)។

ថ្វីត្បិតតែផ្ទៃក្រឡាដែលគ្រប់ដណ្ដប់ដោយព្រៃកោងកាងនៅប្រទេសកម្ពុជា មានទំហំតូចជាងនៅប្រទេសផ្សេងៗ ប្រព័ន្ធអេកូឡូស៊ីរបស់វា មានអត្ថប្រយោជន៍ណាស់ ទាំងក្នុងន័យការប្រើប្រាស់ផ្ទាល់ ទាំងក្នុងន័យការប្រើប្រាស់ មិនផ្ទាល់។ អត្ថប្រយោជន៍ បានពីការប្រើប្រាស់ផ្ទាល់ គឺសំដៅដល់ផលិតផល និងការប្រើប្រាស់ព្រៃកោងកាងទាំងឡាយដោយផ្ទាល់ (ដូចជា ធ្វើអុសដុត ចំណីអាហារ ឬវត្ថុសម្រាប់សាងសង់ ។ល។)។ អត្ថប្រយោជន៍បានពីការប្រើប្រាស់មិនផ្ទាល់ គឺសំដៅដល់ជំនួយ ផ្នែកអេកូឡូស៊ី ដែលផ្ដល់ ដោយព្រៃកោងកាង ជាការជ្រោមជ្រែងដល់សកម្មភាពសេដ្ឋកិច្ចដោយមិនផ្ទាល់ ( ដូចជា ធ្វើជារបាំងធម្មជាតិទប់ស្កាត់មិនឲ្យខូចខាតខ្សែទឹកខាងលើ រក្សាគុណភាពទឹក និងគាំទ្រដល់ជីវិតសត្វផ្សេងៗជាច្រើន)។ ជំនួយប្រព័ន្ធអេកូឡូស៊ីដែលល្បីជាងគេ គឺជំនួយដល់ការនេសាទលក្ខណៈគ្រួសារ និងលក្ខណៈ អាជីវកម្ម។ ព្រៃកោងកាងដើរតួនាទីជាកន្លែងថែទាំ និងជាជម្រកសម្រាប់ពពួកត្រី និងសត្វទឹកសំខាន់ៗដែលមានតម្លៃអាជីវកម្មខ្ពស់។

នៅប្រទេសជិតខាងដូចជាថៃ និងវៀតណាម មានការបំផ្លិចបំផ្លាញយ៉ាងខ្លាំងនូវធនធានធម្មជាតិតាមឆ្នេរសមុទ្រ ដោយសារតែលទ្ធផលនៃការប្រើប្រាស់ដែលមិនមានការគ្រប់គ្រង។ ព្រៃកោងកាងនៅប្រទេសកម្ពុជាសព្វថ្ងៃក៏ស្ថិតក្រោមសម្ពាធខ្លាំងពីការប្រកួតក្នុងការប្រើប្រាស់ធនធានធម្មជាតិដែរ។ ដូចនេះ ត្រូវការយុទ្ធសាស្ត្រគ្រប់គ្រងដែលពេញនិយមជាងគេជាបន្ទាន់ដើម្បីជៀសវាងនូវលទ្ធផលដូចខាងលើ។

## II. ប្រវត្តិនៃការកើត និងតំបន់ដែលមានព្រៃកោងកាងដុះ នៅក្នុងពិភពលោក

### ក. ប្រវត្តិនៃការកើត

ពាក្យ “កោងកាង” ឬ ជាភាសាអង់គ្លេស “mangrove” មានដើមកំណើតតាំងពីឆ្នាំ១៦១៣មកម្លេះ ហើយពាក្យនេះតែងតែត្រូវបានគេគិតថា ជាបន្សំពីពាក្យព័រទុហ្គាល  “mangue” និងពាក្យអង់គ្លេស “grove” ហើយត្រូវនឹងពាក្យបារាំងមានដូចជា “manglier” និង “paletuvier” និងជាភាសាអេស្ប៉ាញ ជា

“manglar” ។ ពាក្យ “mangro” គឺជាឈ្មោះទូទៅសម្រាប់ប្រភេទដើមកោងកាង “Rhizophora” នៅស៊ូរីណាម។ ពាក្យទាំងអស់ខាងលើត្រូវបានគេជឿថា មានប្រភពមកពីពាក្យម៉ាឡេស៊ី “ manggi-manggi ” ដែលមានន័យថា “ពីលើដី”។ ពាក្យនេះ មិនត្រូវបានគេប្រើទេនៅម៉ាឡេស៊ី ប៉ុន្តែត្រូវបានគេប្រើនៅប្រទេសឥណ្ឌូនេស៊ីភាគខាងកើតទៅវិញ ដែលសំដៅដល់ពពួកដើមស្គង់ “Avicennia species”។

កោងកាងមានទំនាក់ទំនងប្រវត្តិសាស្ត្រដ៏យូរលង់មកហើយជាមួយនឹងវប្បធម៌ និងអារ្យធម៌របស់មនុស្សលោក។ ផ្ទះអ្នកតាមានលក្ខណៈដូចៗគ្នានៅប្រទេសអាស៊ី ជាពិសេស នៅឥណ្ឌា ភូមា ថៃឡង់ និងនៅកម្ពុជា។ ទីក្រុងមួយនៅប្រទេសឥណ្ឌាភាគខាងត្បូងបានដាក់ឈ្មោះដែលជាឈ្មោះរបស់ប្រភេទរុក្ខជាតិកោងកាង។ នៅប្រទេសកេនញ៉ា ទីសក្ការៈបូជាទាំងឡាយដែលបានសាងសង់ឡើងនៅក្នុងព្រៃកោងកាង ត្រូវបានប្រជាពលរដ្ឋនៅមូលដ្ឋានគោរពបូជាដោយជឿថា ព្រលឹងរបស់អ្នកតានឹងធ្វើឲ្យអ្នកដែលកាប់ដើមឈើដែលនៅជុំវិញស្លាប់។ នៅកោះសូឡូម៉ូន សាកសពត្រូវបានគេយកទៅបោះបង់ និងប្រារពពិធីលើទឹកនៅក្នុងព្រៃកោងកាង។

ការប្រើប្រាស់រុក្ខជាតិកោងកាងដើម្បីជាប្រយោជន៍ មានពិពណ៌នានៅក្នុងប្រវត្តិសាស្ត្រប្រពៃណីឥណ្ឌា អំពីសង្គ្រាមរវាងរដ្ឋពីរ។ រដ្ឋធំដាក់ផែនការឈ្លានពានរដ្ឋជិតខាងក្នុងពេលយប់ ដែលជារដ្ឋតូច ហើយប៉ុន្តែមានព្រៃកោងកាងដុះលើឆ្នេររបស់ខ្លួន ដែលរំខានដល់សត្រូវ តាមរយៈការដាក់ចង្កៀងបំភ្លឺលើគល់រុក្ខជាតិកោងកាងនៅខាងលើទឹក។ ការណ៍នេះធ្វើឲ្យមើលទៅដូចជាក្រុមនាវាយ៉ាងច្រើនដែលបំបាក់ស្មារតីទ័ពឈ្លានពាន និងចុងក្រោយលែងចង់បង្កើតឲ្យមានសង្គ្រាមទៀត។

## ខ. តំបន់ដែលមានព្រៃកោងកាងដុះ

មានតំបន់ព្រៃកោងកាងពីរសំខាន់នៅក្នុងពិភពលោក: នៅអឌគោលខាងកើត និងអឌគោលខាងលិច។ អឌគោលខាងកើត គឺតំបន់ឥណ្ឌូខាងលិចប៉ាស៊ីហ្វិច ដែលមានអាហ្វ្រិចខាងកើត ឥណ្ឌូ–ម៉ាឡេស៊ី និងអូស្ត្រាលី។ អឌគោលខាងលិច គឺតំបន់អាត្លង់ទិចនិងប៉ាស៊ីហ្វិចខាងកើត ដែលមានអាមេរិចខាងលិច អាមេរិចខាងកើត និងអាហ្វ្រិចខាងលិច។ អឌគោលខាងកើត ជាកន្លែងប្រភពដើមនៃការកកើតរុក្ខជាតិកោងកាង ហេតុដូចនេះហើយ តំបន់នេះត្រូវបានគេហៅថា ពិភពព្រៃកោងកាងចាស់ (Old World Mangroves) និងអឌគោលខាងលិច ជាពិភពព្រៃកោងកាងថ្មី (New World Mangroves)។ នៅអឌគោល ខាងកើតមានពពួកកោងកាងចំនួន៤៩ប្រភេទ គឺច្រើនប្រភេទជាងនៅអឌគោលខាងលិច ដែលមានតែ ១១ប្រភេទ។

នៅក្នុងការប៉ាន់ស្មានអំពីផ្ទៃដីដែលមានព្រៃកោងកាងដុះសម្រាប់ប្រទេសនីមួយៗមានជួបប្រទះការលំបាក ដោយសារហេតុផលមួយចំនួន:

១. មិនមានទិន្នន័យគ្រប់គ្រាន់សម្រាប់ប្រទេសមួយចំនួន ជាពិសេសនៅអាហ្វ្រិចខាងលិច និងនៅ អាស៊ី។

២. តំបន់ព្រៃកោងកាងនៅប្រទេសកំពុងអភិវឌ្ឍជាច្រើន មានការបាត់បង់ទៅវិញយ៉ាងឆាប់។

៣. មិនមានវិធីសាស្ត្រស្តង់ដាររួមណាមួយក្នុងការប៉ាន់ស្មានផ្ទៃក្រឡាតំបន់ព្រៃកោងកាងនៅប្រទេសផ្សេងៗ ដែលជាលទ្ធផលធ្វើឲ្យមានការលំបាកក្នុងការប្រៀបធៀប។

៤. មានការលំបាកក្នុងការញែកគ្នាឲ្យដាច់រវាងព្រៃដែលនៅលើគោក និងដើមកោងកាងនៅកន្លែង ដែលមានដើមកោងកាងខ្ពស់ៗនៅលាយឡំជាមួយដើមឈើផ្សេងៗទៀត។

៥. មិនមានការបែងចែកបានច្បាស់លាស់រវាងការលាតសន្ធឹងរបស់ផ្ទៃទឹក និងផ្ទៃដីកោងកាងដោយសារតែបញ្ហាទឹកជោរទឹកនាច។

៦. ក្រៅពីបញ្ហាខាងលើ មានបញ្ហាមួយទៀតដែលទាក់ទងនឹងការឲ្យនិយមន័យមិនច្បាស់លាស់សម្រាប់ប្រភេទពូជកោងកាង និងហេតុដូច្នេះហើយបានជាក្នុងករណីជាច្រើនមានប្រភេទពូជផ្សេងៗទៀតដែលដុះលើដីល្បាប់ និងប្រភេទរុក្ខជាតិបន្លែផ្សេងៗទៀតក៏ត្រូវបានរាប់បញ្ចូលដែរ។

**តារាង១**ផ្តល់នូវផ្ទៃដីប៉ាន់ស្មានដែលគ្របដណ្តប់ដោយព្រៃកោងកាងនៅក្នុងពិភពលោកទាំងមូល។ ផ្ទៃដីគ្របដណ្តប់ដោយព្រៃកោងកាងសរុបទូទាំងពិភពលោកមានចំនួន ១៨លានហិចតា ស្មើនឹង០.៤៥% នៃព្រៃឈើ និងដីព្រៃឈើសរុបពិភពលោកប៉ុណ្ណោះ។ ៩១.៤%នៃផ្ទៃដីកោងកាងសរុបមាននៅទ្វីបអាស៊ីខាងត្បូង និងអាស៊ីអគ្នេយ៍។

**តារាង១.ផ្ទៃដីគ្របដណ្តប់ដោយព្រៃកោងកាង**

| តំបន់ | ផ្ទៃក្រឡា(គម$^{២}$) | គិតជាភាគរយ |
|---|---|---|
| អាស៊ីខាងត្បូង និងអគ្នេយ៍ | ៧៥,១៧០ | ៤១.៥ |
| អាមេរិច | ៤៩,០៩៦ | ២៧.១ |
| អាហ្វ្រិចខាងលិច | ២៧,៩៩៥ | ១៥.៥ |
| អូស្ត្រាលី | ១៨,៧៨៨ | ១០.៤ |
| អាហ្វ្រិចខាងកើត និងមជ្ឈឹមបូព៌ា | ១០,៣៤៨ | ៥.៧ |

ប្រភព: Kathiresan, Center of advanced study in Marine Biology, Annamalai University

ព្រៃកោងកាងបានពង្រាយខ្លួននៅលើផ្ទៃដី១១២ប្រទេស។ **តារាង២** បង្ហាញផ្ទៃដីកោងកាងសំខាន់ៗនៅក្នុង១៥ប្រទេស។ តំបន់ព្រៃកោងកាងដែលធំជាងគេ មាននៅឥណ្ឌូណេស៊ី ប្រេស៊ីល អូស្ត្រាលី និងនីហ្សេរីយ៉ា ដែលមានចំនួនរៀងគ្នា ៣០% ១០% ៨% និង៧%នៃផ្ទៃដីកោងកាងសរុបលើពិភពលោក។

**តារាង២.ផ្ទៃដីកោងកាងប៉ាន់ស្មាននៃ១៥ប្រទេសដែលមានតំបន់កោងកាងធំជាងគេ**

(after ITTO/ISME, 1993)

| ប្រទេស | ផ្ទៃដីកោងកាង(១០០០ហាត) | ភាគរយក្នុងពិភពលោក(%) |
|---|---|---|
| ឥណ្ឌូណេស៊ី | ៤២៥០ | ៣០ |
| ប្រេស៊ីល | ១៣៧៦ | ១០ |

| | | |
|---|---|---|
| អូស្ត្រាលី | ១១៥០ | ៨ |
| នីហ្គារី | ៩៧០ | ៧ |
| ម៉ាឡេស៊ី | ៦៤១ | ៥ |
| បាំងក្លាដេស | ៦១១ | ៤ |
| មីយ៉ានម៉ា | ៥៧០ | ៤ |
| វៀតណាម | ៥៤០ | ៤ |
| គុយបា | ៥៣០ | ៤ |
| ម៉េកស៊ិក | ៥២៥ | ៤ |
| ស៊ុណេហ្គាល | ៤៤០ | ៣ |
| ឥណ្ឌា | ៣៦០ | ៣ |
| កូឡុំប៊ីយ៉ា | ៣៥៨ | ៣ |
| កាមេរ៉ូន | ៣៥០ | ២ |
| ម៉ាដាហ្គាស្កា | ៣២៧ | ២ |

ប្រភព: Kathiresan, Center of advanced study in Marine Biology, Annamalai University

## III. ស្ថានភាពព្រៃកោងកាងនៅព្រះរាជាណាចក្រកម្ពុជា

ព្រៃកោងកាងមាននៅតាមបណ្តោយឆ្នេរសមុទ្រកម្ពុជាដែលជាញឹកញាប់បង្កើតបានជារបងការពារតាមបណ្តោយឆ្នេរសមុទ្រ និងទៅតាមមាត់ទន្លេ ឬព្រែកធំៗដែលហូរធ្លាក់ទៅក្នុងសមុទ្រ។ ដូចក្នុងករណីពិភពលោកទូទៅដែរ ការវាយតម្លៃផ្ទៃដីកោងកាងនៅប្រទេសកម្ពុជាជួបប្រទះនូវការលំបាកទាំងឡាយដូចបានរៀបរាប់ខាងលើ។ ភាពខុសគ្នានៅក្នុងវិធីសាស្ត្រ ចំណាត់ថ្នាក់ ការគូរផែនទី ការកំណត់មាត្រដ្ឋាន។ល។ អាចនាំទៅរកភាពខុសគ្នានៃតួលេខទាំងឡាយ។ **តារាង៣ និង៤** ផ្តល់នូវកម្រិតទាំងអស់នៃពត៌មានដែលអាចទទួលបានអំពីផ្ទៃដីកោងកាងនៅប្រទេសកម្ពុជា។

**តារាង៣. ផ្ទៃដីកោងកាងនៅប្រទេសកម្ពុជា**

| ឆ្នាំ | ផ្ទៃក្រឡា (ហិចតា) | ប្រភព | និន្នាការ | វិធីសាស្ត្រ/ ការអត្ថាធិប្បាយ |
|---|---|---|---|---|
| ១៩៥០ | ១០០ ៧០០ | BIM ( Biodiversity Information Management System). 1997.Indo-Malayan Realm Study Final report | | ជាតួលេខដើម មិនមានអត្ថាធិប្បាយអំពីវិធីសាស្ត្រជាក់លាក់។ តួលេខនេះហាក់អាចទុកចិត្តបាន ប៉ុន្តែវាមិនត្រូវបានយកមកប្រើប្រាស់សម្រាប់ការវិភាគអំពីនិន្នាការឡើយ ពីព្រោះវាចាស់ពេកសម្រាប់ការសិក្សានេះ។ |
| ១៩៧០ | ៩៥ ៨០០ | Nirmal Chandra, P. 1998. Mangrove Area Encroachment in Cambodia: Problems and findings. Paper presented at the | | ជាឯកសារយោងទី២។ មិនមានបង្ហាញប្រភពដើម។ |

| | | | | |
|---|---|---|---|---|
| | | seventh annual conference of the International Association for the Study of Common Property, Crossing Boundaries. Vancouver, British Colombia, Canada, June 10-14 | | |
| ១៩៧៥ | ៩៥ ៦០០ | The Mekong Secretariat, UNDP, FAO. 1994. Cambodia Land Cover Atlas. 1985/87-1992/1993 ( including national and provincial statistics). Remote sensing & Mapping unit, Mekong Secretariat, UNDP, FAO, Cambodia 124 pp. | | ដឹងពីចម្ងាយ ឬសិក្សាពីចម្ងាយ |
| ១៩៨៣ | ១០ ០០០ | Wacharakitty, S. 1983. Mangrove Ecosystem in General. In: ESCAP/UNSESCO/NRCT Regional Remote Sensing Training Course of Mangrove Ecosystem. P. 22-23. Bangkok, Nov. 28-Dec. 16, 1983 | | មាននៅ: FAO. 1994. និយាយពីគោលការណ៍ណែនាំលើការគ្រប់គ្រងព្រៃកោងកាង។ FAO Forestry Paper 117. Rome, 319 pp. តួលេខនេះប្រហែលជាមានការបោះពុម្ពអក្សរខុស។ |
| ១៩៨៦ | ៦៨ ៥០០ | The Mekong Secretariat, UNDP, FAO. 1994. Cambodia Land Cover Atlas. 1985/87-1992/1993 ( including national and provincial statistics). Remote sensing & Mapping unit, Mekong Secretariat, UNDP, FAO, Cambodia 124 pp. | | ដឹងពីចម្ងាយ ឬសិក្សាពីចម្ងាយ |
| ១៩៨៨ | ៨៣ ៧០០ | Nirmal Chandra, P. 1998. Mangrove Area Encroachment in Cambodia: Problems and findings. Paper presented at the seventh annual conference of the International Association for the Study of Common Property, Crossing Boundaries. Vancouver, British Colombia, Canada, June 10-14 | | Lansat 1988-89/LUMA 1992. រូបភាពដែលបានមកដោយថតពីផ្កាយរណប ។ មិនមានផ្តត់ផ្គង់ឯកសារគ្រប់គ្រាន់។ |
| ១៩៨៩ | ៦០ ១០០ | Spalding, M.D., Blasco, F. and Field, C.D., eds. 1997. World Mangrove Atlas. The International Society for Mangrove Ecosystems, Okinawa, Japan. 178 pp. | | ការវិភាគលើផែនទី1: 500 000. ទិន្នន័យផ្ទៃដីកោងកាង ត្រូវបានបំលែងជាលេខពីលេខាធិការដ្ឋានទន្លេមេគង្គ (១៩៩១) ដែលផ្អែកលើ១៩៨៨/៩ Landsat |

| | | | | |
|---|---|---|---|---|
| | | | | TM images (រូបភាពដែលបានមកដោយថតពីផ្កាយរណប) ដែលបានបកស្រាយដោយគ្មានការសង្កេតនៅខាងក្រោម។ យោងតាមអ្នកនិពន្ធ |
| ១៩៩២ | ៨៥ ១០០ | The Mekong Secretariat, UNDP, FAO. 1994. Cambodia Land Cover Atlas. 1985/87-1992/1993 ( including national and provincial statistics). Remote sensing & Mapping unit, Mekong Secretariat, UNDP, FAO, Cambodia 124 pp. | X | ដឹងពីចម្ងាយ ឬសិក្សាពីចម្ងាយ |
| ១៩៩៣ | ៧៧ ៦៦៩ | Department of Forestry and Wildlife, Forest Wildlife Research and Education Institute. 1998 Forest Cover Statistics. | | ទិន្នន័យដែលបកស្រាយដោយការមើលឃើញពីចំងាយ ធ្វើការវិភាគជាមួយជំនួយបច្ចេកវិទ្យា GIS។ |
| ១៩៩៧ | ៧២ ៨៣៥ | Department of Forestry and Wildlife, Forest Wildlife Research and Education Institute. 1998 Forest Cover Statistics. | X | ទិន្នន័យដែលបកស្រាយដោយការមើលឃើញពីចំងាយ ធ្វើការវិភាគជាមួយជំនួយបច្ចេកវិទ្យា GIS។ |

ប្រភព: FAO, 2005, Forestry Department, Global Forest Resources Assessment

X= អាចទុកចិត្តបាន

**តារាង៤. ស្ថានភាពផ្ទៃដីកោងកាងក្នុងអំឡុងពេលផ្សេងៗ**

| ឆ្នាំ | ១៩៨០ | ១៩៩០ | ១៩៩៧ | ២០០០ | ២០០៥ |
|---|---|---|---|---|---|
| ផ្ទៃក្រឡា(ហិចតា) | ៩១,២០០ | ៨២,៤០០ | ៧២,៨៣៥ | ៧៣,៦០០ | ៦៩,២០០ |

ប្រភព: FAO, 2005, Forestry Department, Global Forest Resources Assessment

ចំនួនផ្ទៃក្រឡាដែលបង្ហាញក្នុងតារាង៤ ជាការប៉ាន់ស្មានចុងក្រោយបង្អស់ ក៏ប៉ុន្តែក្នុងពេលនៃកិច្ចសម្ភាសន៍ជាមួយអ្នកដែលធ្វើការក្នុងវិស័យនេះនៅឆ្នាំ២០១១ បានផ្តល់នូវផ្ទៃក្រឡាប៉ាន់ស្មានដូចខាងក្រោម:

ផ្ទៃក្រឡាកោងកាងសរុប: ៧៨,៤០៥ ហិចតា

ខេត្តកោះកុង ៦២,០០០ ហិចតា

ខេត្តព្រះសីហនុ ១៣,៥០០ ហិចតា

ខេត្តកំពត ១,៩០០ ហិចតា

ខេត្តកែប ១,០០៥ ហិចតា

## ក. ការពិពណ៌នាអំពីរុក្ខជាតិ

ពាក្យ ( Mangrove) ជាភាសាខ្មែរហៅថាកោងកាង ឬហៅព្រៃមុខព្រែកដែលមានន័យថាព្រៃតាមមាត់ទន្លេ អាចចែកចេញជាប្រភេទផ្សេងៗ:

១. ពូជនាំមុខគេ មានទីតាំងនៅតំបន់លិចទឹកជាប្រចាំ ដែលផ្សំឡើងដោយពួកដើមត្បាញ ឬដើមស្គង់សុទ្ធ (Avicennia)។ ប្រភេទបែបនេះ ជាទូទៅមាននៅក្នុងតំបន់ទល់មុខកោះថ្មី។

២. ពូជនៅមាត់ច្រាំងដែលនៅតាមបណ្តោយមាត់ព្រែក ឬអូរតូចចង្អៀត។ នៅមាត់ព្រែកកំប៉ូង់ជាពួកដើមកោងកាង(Rhizophora conjugata)សុទ្ធដែលដើមវាមានអង្កត់ផ្ចិតពី១៥ ទៅ២០សង់ទីម៉ែត្រ និងមានកំពស់ពី១០ ទៅ១៥ម៉ែត្រ។ ជាទូទៅព្រៃឈើពពួកនេះជាព្រៃក្រាស់ ពីព្រោះការចេញពន្លករបស់វានៅលើដើមរបស់វាតែម្តង។ បន្ទាប់មកកូនពន្លកទាំងនោះក៏ធ្លាក់លើភក់ ហើយកូនឈើតូចៗក៏បន្តការរីកធំធាត់របស់ខ្លួន។ នៅតាមបណ្តោយព្រែកបន្តទៀតមានជួបប្រភេទក្រញឹប( Lumnitzera) ជាកំប៉ូតៗ ដែលមានកំពស់ពី២០ ទៅ២៥ម៉ែត្រ។ នៅក្នុងបរិវេណព្រែកពីផាត់ ជាប្រភេទដើមឈើដុះចម្រុះដែលមានដូចជា Sindora ដើម សិរមាន់សមុទ្រ ឬដើមសិរមាន់ទឹកប្រៃ (Hertiera littoralis) ដើម Carapha obovata ដើមអំពូ (Sonneratia excoecaria) ដើមចាក (Nipa fruticans) ដើមLicuala ferns  និងដើមបើស ឬដើម កប្បាស់ព្រៃទឹកប្រៃ( Hibiscus tiliaceus)។

៣. ពូជកោងកាងពិត

ពូជកោងកាងពិតផ្សំឡើងដោយពពួក Rhizophora ពីរយ៉ាង គឺ Rhizophora conjugata និង ដើមកោងកាងស្លឹកធំ (Rhizophora mucronata) ដុះតាមបណ្តោយឆ្នេរសមុទ្រ។ មួយប្រភេទ ដុះឆ្ងាយពីមាត់សមុទ្រ ហើយខ្ពស់ៗឡើងទៅលើ និងមានចំនួនកាន់តែតិចទៅៗ ក្លាយជាព្រៃ របោះដែលផ្តុំឡើងពី Rhizophora conjugata ជាមួយនឹងពពួកដើមបាសាក់ក្រហម (Bruquiera gymnorhiza)។ ពពួកនេះច្រើនមាននៅកណ្តាលកោះ ឧទាហរណ៍ ចំងាយ២០០ម ឆ្ងាយពីមាត់ សមុទ្រនៅលើកោះដែលជាកោះតូចគ្របដណ្តប់ដោយដើមកោងកាង( Rhizophora conjugata) ដែលមានកំពស់ពី១០ ទៅ១៥ម និងដើមមានអង្កត់ផ្ចិតពី១៥ ទៅ២០សង់ទីម៉ែត្រ។

៤. ប្រភេទដើមកោងកាងចម្រុះ

ប្រភេទនេះជាធម្មតាមានតែនៅលើដីដែលជនលិចទឹកពេលមានជំនោរ។ ប្រភេទនេះសម្បូរណ៍ជាងប្រភេទកោងកាងពិត។ ដើមកោងកាង( Rhizophora conjugata) និងដើម បាសាក់ក្រហម (Bruquiera gymnorhiza)មានចំនួនច្រើន។ ដើមក្រញឹប (Lumnitzera coccinea) ដើម Carapa obovata ដើមបើស ឬដើមកប្បាសព្រៃទឹកប្រៃ (Hibiscus tiliaceus)។ ជួនកាលឃើញមានពពួកដើមសិរមាន់សមុទ្រ( Heritiera littoralis) ដើមស្មែ( Ceriops) ដើម( Melaleuca leucadendron) និងដើមប្រង់ ឬដើមខ្នាញ់( Acrostichum)។ ពពួកព្រៃនេះ ជាព្រៃល្បោះ ច្រើនមានពួកដើមកោងកាង( Rhizophora)  និងដើមស្មែ (Ceriops) កាលណាគេឡើងតាមដងទន្លេ។

៥. ប្រភេទកោងកាងជិតផុតពូជ

ក្នុងចំណោមដើម( Melaleuca leucadendron)ក៏មានដុះព្រៃកោងកាងដែរ។ ជួនកាលមានសំណល់កោងកាងនៅកន្លែងដែលទឹកសមុទ្រលែងទៅដល់ ហើយលែងមានពពួកដើមកោងកាង (Rhizophora) តែម្តង និងសង្កេតឃើញមានតែពពួកដើមបាសាក់ (Bruquiera) ដើម (Sonneratia) និងដើមក្រូចកនាងដៃ (Aegiceras )តែមួយចំនួនប៉ុណ្ណោះ។

## ខ. ការពិពណ៌នាអំពីសត្វ

ថនិកសត្វមួយចំនួនធំទៅជ្រកកោនរកស៊ីនៅកន្លែងព្រៃកោងកាង ក៏ប៉ុន្តែក្នុងចំណោមសត្វទាំងនោះមានតែមួយចំនួនតូចប៉ុណ្ណោះដែលរស់នៅជាអចិន្ត្រៃយនៅទីនោះ ហើយមានមួយចំនួនកាន់តែតូចមិនអាចទៅតំបន់ព្រៃកោងកាងតែម្តង។ នៅទីនេះគេសង្កេតឃើញមានសត្វស្វាស៊ីក្តាមម្យ៉ាង(Macaca) និងជ្រូកព្រៃ(Sus scrofa)និងសត្វឈ្លូស។ សត្វភេក៏មាននៅក្នុងព្រៃកោងកាងដែរ។ ជួនកាលឃើញមានស្ទាមជើងឆ្មាត្រី(Prionailurus viverrinus)ដែរ។

ការរកចំណីរបស់បក្សីមានលក្ខណៈធូធារនៅក្នុងព្រៃកោងកាង ប៉ុន្តែមានតែប្រភេទបក្សីមួយចំនួនប៉ុណ្ណោះដែលធន់នឹងលក្ខខ័ណ្ឌរស់នៅព្រៃកោងកាង។ ជាទូទៅមានសត្វក្រសារ (Heron) និងសត្វអង្កត់ខ្មៅ (Cormorant or Phalacrocorax)។ បក្សីផ្សេងទៀតក៏សង្កេតឃើញមានដែរ ដូចជារនាលស(Milky stork) និងត្រដក់តូច(Lesser adjutant)។ សត្វប្រជៀវដែលចូលចិត្តដើមឈើធំៗជាទ្រនំ (Large Fruit bat or Flying Foxe) ក៏ប្រើប្រាស់តំបន់ឆ្នេរសមុទ្រតាមរដូវកាលសម្រាប់ជាជំរករបស់ខ្លួន។

ក្នុងចំណោមឧរង្គសត្វ ឬសត្វលូនសម្បូរណ៍ជាងគេ គឺសត្វពស់។

ក្រៅពីនេះទៀត នៅក្នុងតំបន់ព្រៃកោងកាង មានប្រព័ន្ធអេកូឡូស៊ីរបស់សមុទ្រ និងឆ្នេរសមុទ្រដែលក្នុងនោះមានវាលស្មៅសមុទ្រ និងផ្កាថ្មផ្សេងៗ។ វាលស្មៅសមុទ្របានផ្តល់នូវកន្លែងបង្កាត់ពូជ និងការនេសាទដ៏សំខាន់ដែលក្នុងនោះមានដូចជាជ្រូកទឹក **Dugong** (Dugong Dugong) និងអណ្តើកសមុទ្របៃតង (Chelonia mydas)។ ប្រភេទអណ្តើកបែបនេះត្រូវបានគេដឹងថាមាននៅព្រែកស្រែអំបិល និងព្រែកក្អោង។

## គ. ការពិពណ៌នាអំពីផ្កាថ្ម និងស្មៅសមុទ្រ

ផ្កាថ្ម និងស្មៅសមុទ្រឃើញមាននៅតំបន់សមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ជាមួយការលោតសន្ទឹងយ៉ាងខ្លាំងនៅតំបន់ខេត្តកំពត និងខេត្តកែប។ នៅឆ្នាំ២០០០ ធនាគារអភិវឌ្ឍអាស៊ីបានធ្វើការប៉ាន់ស្មានទំហំផ្ទៃក្រឡាដែលគ្រប់ដណ្តប់ដោយផ្កាថ្មមាន៤៧៦ហិចតា ស្មៅសមុទ្រមាន១៧៥ហិចតា និងផ្ទៃដីឆ្នេរសើមមាន៥៤,៥០០ហិចតា។

ការគម្រាមកំហែងផ្សេងៗចំពោះផ្កាថ្មនៅប្រទេសកម្ពុជាមានលក្ខណៈដូចគ្នាដូចធ្លាប់បាន ជួបប្រទះនៅប្រទេសជិតខាងដែរ ដែលក្នុងនោះមានការនេសាទមិនត្រឹមត្រូវ ដូចជាប្រើមង ឬសំណាញ់ម៉ាស៊ីនញ៉ឹក ការអូសអួននៅកន្លែងទឹករាក់ និងមងដែលមានបាតធ្ងន់ដែលធ្វើឲ្យខូចខ្ទី និងបំផ្លាញដល់វាលស្មៅសមុទ្រ ការនេសាទដោយប្រើគ្រាប់បែក និងCyanide ការប្រមូល ផ្កាថ្មសម្រាប់លក់ និងការធ្លាក់ចុះនៃ

គុណភាពទឹកដោយសារការបោះចោលកាកសំណល់ ដោយប្រជាពលរដ្ឋក្នុងតំបន់ និងកាកសំណល់ឧស្សាហកម្ម។

## IV. ការប្រើប្រាស់រុក្ខជាតិកោងកាង

ដូចធ្លាប់បានធ្វើការកត់សម្គាល់ខាងលើរួចមកហើយថា រុក្ខជាតិកោងកាងមានតម្លៃប្រើ ប្រាស់ផ្ទាល់ និងមិនផ្ទាល់។

### ១. តម្លៃប្រើប្រាស់ផ្ទាល់

#### ក.ការសាងសង់

ជាញឹកញាប់គេប្រើប្រាស់ឈើកោងកាងសម្រាប់សង់ផ្ទះ ទូក និងរបងផ្សេងៗ។ ប្រភេទដើមកោងកាងស្លឹកធំ (Rhizophora mucronata) មានលក្ខណៈសាកសមបំផុតក្នុងការធ្វើរបង ធ្នឹម និងគ្រឹះផ្ទះ។ ទីខាងមុខផ្ទះដែលធ្វើឡើងដោយដើមកោងកាងត្រូវបានគេឃើញ នៅពីមុខផ្ទះភាគច្រើន នៅភូមិនេសាទតាមបណ្តោយឆ្នេរ និងត្រូវបានប្រើប្រាស់សម្រាប់សម្ងួតត្រី និងបង្គារ។ សសរដើមកោងកាងក៏ត្រូវបានប្រើប្រាស់ធ្វើជាគ្រោងសម្រាប់ប្រក់ស្បូវពីលើ និងគ្រឿងប្រដាប់សម្រាប់នេសាទ។

#### ខ.ធ្វើអុសដុត

អុសគឺជាធនធានដ៏សំខាន់ដែលប្រមូលបានពីព្រៃកោងកាងត្រូវបានប្រើប្រាស់សម្រាប់ចំអិនអាហារ។ ប្រជាពលរដ្ឋតំបន់ឆ្នេរតិចជាង១០%ប្រើប្រាស់ឧស្ម័ន។ ជាក់ស្តែងគ្រប់ប្រភេទកោងកាង ទាំងអស់ត្រូវបានប្រើប្រាស់ជាអុសដុត ប៉ុន្តែចរឹតលក្ខណៈនៃការឆេះរបស់វាផ្សេងៗ គ្នា។ ដើមកោងកាង ( Rhizophora spp. )ត្រូវបានពេញនិយមបំផុត ព្រោះជាឈើធ្ងន់ ហើយការឆេះរបស់វា ក៏ផ្តល់កំដៅខ្លាំង។ វាក៏អាចបញ្ចេញខ្យល់ដ៏ស្អាតជាមួយនឹងផ្សែងតិចៗ វាងាយឆេះពេលស្ងួតមិនសព្វក៏ដោយ និងងាយពុះជ្រៀក។ គ្រួសារដែលមានសមាជិកជាមធ្យម៦នាក់ប្រើប្រាស់ប្រហែលជា៩ម៉ែត្រគូបក្នុងមួយឆ្នាំ។ ក្រៅពីដើម Rhizophora ដើមក្បាញ ឬដើមស្តង់(Avicennia spp.) និងដើមឈើជ័រ ឬដើមតាទុំ(Excoercia spp.) ផ្តល់អុសជាប្រភពថាមពលសម្រាប់សិប្បកម្មធ្វើឥដ្ឋ និងក្បឿង។

#### គ.ធ្វើធ្យូង

ប្រជាជននៅតំបន់ឆ្នេរប្រើប្រាស់ធ្យូងកោងកាងបន្ថែមដើម្បីជំនួសអុសក្នុងការចំអិនអាហារ។ ចំនួនប្រជាពលរដ្ឋដែលប្រើប្រាស់ធ្យូងប្រហែលជា២០%។ ផលិតផលធ្យូងមួយភាគធំត្រូវបានលក់ទៅទីប្រជុំជន និងមួយចំនួនទៀតនាំចេញទៅប្រទេសជិតខាង។

ដើមកោងកាង( Rhizophora spp.) បង្កើតបានជាធ្យូងដែលមានគុណភាពល្អខ្លាំង។ ប្រភេទកោងកាងផ្សេងទៀត ដូចជាដើមបាសាក់ក្រហម (Bruquiera gymnorhiza) និងដើមស្មែ ( Ceriops) ក៏ត្រូវបានប្រើប្រាស់ធ្វើធ្យូងដែរតែមិនសូវសំខាន់នោះទេ។

សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ការផលិតធ្យូងកោងកាងធ្វើឡើងនៅក្នុងឡតូចៗ។ ហេតុដូច្នេះគុណភាពរបស់វាមានកម្រិតទាប ហើយថ្លៃរបស់វាក៏ទាបដែរ។

នៅក្នុងផលិតកម្មសម្រាប់ធ្វើអាជីវកម្មវិញ ធ្យូងកោងកាងត្រូវបានផលិតនៅក្នុងឡមាន ទម្រង់ជាគូប ធ្វើពីដីភក់លាយចូលគ្នា ឬពីកំបោរ ឬស៊ីម៉ង់នៅកន្លែងខ្ពស់ក្នុងព្រៃកោងកាង ឬនៅបរិវេណក្បែរព្រៃកោងកាង។ ទំហំឡជាមធ្យម អាចផ្ទុកឈើជិត១៥បាច់ (Cords) ហើយដំណើរការនៃការដុតឈើឲ្យទៅជាធ្យូងទាមទាររយៈពេលពី១៨ ទៅ៤០ថ្ងៃ។ ក្នុងដំណាក់ កាលទី១ឈើត្រូវបានគេដុតក្នុងឡដែលចំហរទ្វារ។ បន្ទាប់មកគេយកឥដ្ឋបិទទ្វារ ដោយទុករន្ធ តូចៗដើម្បីឲ្យខ្យល់ចេញចូល។ បន្ទាប់ពី ២ ទៅ៣ថ្ងៃមកទើបគេបិទរន្ធទាំងនោះ ហើយពន្លត់ ភ្លើងទុកឲ្យត្រជាក់។ ប្រតិបត្តិករដែលមានជំនាញគ្រប់គ្រងដំណើរការនេះ អាចពិនិត្យមើលតាមរយៈពណ៌ និងក្លិនផ្សែងរបស់វា។ ទម្ងន់ធ្យូងដែលបានផលពីការដុតអុសស្រស់មិនមានភាពទៀងទាត់ឡើយ។ ការប្រើឈើកោងកាងស្រស់ដើម្បីធ្វើជាធ្យូង គឺបានប្រហែល ១២៥គក្រ/មួយបាច់សម្រាប់(Rhizophora spp.) និង១២០គក្រ/មួយបាច់សម្រាប់(Bruquiera spp.)។

### ឃ.ធ្វើល័ក្ខ

ល័ក្ខត្រូវបានគេប្រើប្រាស់ដើម្បីជ្រលក់ពណ៌ក្រណាត់ និងមងនេសាទ។ ដើមស្មែ ( Ceriops)ផ្តល់គុណភាពល័ក្ខល្អជាងគេ ហើយប្រើប្រាស់សម្រាប់ជ្រលក់ពណ៌ក្រណាត់។ ល័ក្ខបានពី(Rhizophora spp.) និង ដើមក្រញឹប (Lumnitzera spp.)ប្រើសម្រាប់ជ្រលក់សំណាញ់នេសាទ។

ក្នុងមួយបាច់( Cord)ដើមកោងកាងមានទម្ងន់ជាមធ្យម៥០០គីឡូក្រាម។ នេះធ្វើ ឲ្យការចំណាយក្នុងការដឹកជញ្ជូនខ្ពស់ ឬក៏មិនអាចទៅរួច។ ម្យ៉ាងទៀតមានការប្រើប្រាស់ សំណាញ់ ឬមងនីឡុងទៀត ធ្វើឲ្យការប្រើល័ក្ខពីឈើកោងកាងក្នុងការជ្រលក់ពណ៌មង ត្រូវបានកាត់បន្ថយ។

### ង.ដើមចាក

ដើមចាក“Nypa fruticans” ជារុក្ខជាតិដែលមានសារៈសំខាន់ណាស់។ ជានិច្ចជាកាលវាដុះនៅលើដីដែលមានទឹកសមុទ្រជន់លិច។ ស្លឹករំយចំណាស់ត្រូវបានប្រើប្រាស់ដើម្បីប្រក់ដំបូលផ្ទះ ស្លឹកខ្ចីត្រូវបានបូតចេញពីទ្រនុងវាយកទៅចងភ្ជាប់នឹងឬស្សីដោយប្រើវល្លិ ។ ដំបូលស្លឹកចាកអាចមានជីវិតពី៣ ទៅ៥ឆ្នាំក្នុងការប្រើប្រាស់។ ស្រទាប់ស្លឹកខាងក្រោមនៃស្លឹកចាកខ្ចីៗត្រូវបានប្រើប្រាស់សម្រាប់មូរបារីជក់។ ទឹកចេញពីដើមចាក អាចរម្ងាស់ធ្វើជាស្ករ ស្រាស និងទឹកខ្មេះ។

### ច.ការនេសាទ

ព្រៃកោងកាងមានតួនាទីភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធអេកូឡូស៊ីដីគោក និងទឹកសមុទ្រ។ នេះជាការបញ្ជូនចូលនៃសារធាតុឥតជីវិតពីដីគោកទៅក្នុងព្រៃកោងកាង និងបញ្ជូនចេញនូវសារធាតុមានជីវិតពីព្រៃកោងកាងចូលទៅក្នុងទឹកសមុទ្រ។ អត្ថប្រយោជន៍របស់ព្រៃកោងកាងក្នុងនាមជាប្រភពចំណីអាហារជាជំរក និងជាការថែទាំការពារ ទាំងការចិញ្ចឹម ទាំងការនេសាទត្រីតាមបណ្តោយឆ្នេរសមុទ្រកម្ពុជានៅមិនទាន់ត្រូវបានគេយល់ច្បាស់នៅឡើយទេ ប៉ុន្តែត្រូវបានគេគិតថាមានតម្លៃខ្ពស់។

ការសិក្សាអំពីដើមកោងកាងស្លឹកតូច(Rhizophora apiculata ) នៅភាគខាងត្បូងនៃប្រទេសថៃ បានបង្ហាញថា សារធាតុមានជីវិតលើដី គឺមានប្រហែល៧តោនជាស្លឹក និង២០តោនជាឈើក្នុង១ហិតតា

ក្នុង១ឆ្នាំ។ Phytoplanktonក្នុងតំបន់ឆ្នេរទឹក គឺមានកាបោន ឬធ្យូងក្នុងរង្វង់៥០០មីលីក្រាម/ម$^{២}$/១ថ្ងៃ។ តើការណ៍ជះឥទ្ធិពលលើផលិតផល ត្រីយ៉ាង ណានោះ គេនៅមិនទាន់យល់ច្បាស់នៅឡើយរហូតមកដល់សព្វថ្ងៃ។

ប្រភេទបង្គារភាគច្រើនដូចជា ( Metapenaeus spp, Acetes spp, Penaeus spp.) ពងនៅឆ្ងាយពីច្រាំងសមុទ្រ ដោយប្រើប្រាស់ព្រៃកោងកាងជាជំរំ និងជាកន្លែងរកចំណី ចិញ្ចឹមក្នុងអំឡុងពេលនៃដំណាក់កាលចុងក្រោយ។ បង្គារត្រូវគេនេសាទដោយប្រើអួន និងមងកន្ត្រៃ(Scissor net)។ មងកន្ត្រៃ ឬមងរុញផ្គុំឡើងដោយសំណាញ់រាងជាកន្ត្រក ឬកញ្ច្រែង ដែលចងភ្ជាប់ទៅ នឹងចុងទាំងសងខាងនៃដងឬស្សី។ គេច្រើនប្រើវាជាមួយទូកតូចៗ ហើយមិនអាចធ្វើ ប្រតិបត្តិការបានក្នុងលក្ខខ័ណ្ឌអាកាសធាតុមិនល្អនោះទេ។

ក្ដាមភក់សមុទ្រ (Scylla serrata) ត្រូវបានគេឲ្យតម្លៃខ្ពស់ និងបង្កើតបានជាកសិដ្ឋានដ៏មានតម្លៃប៉ុន្តែខ្នាតតូច ។ រហូតមកដល់បច្ចុប្បន្ន ចំនួនក្ដាមភាគច្រើនត្រូវបានគេនេសាទ តាមរយៈឧបករណ៍ចាប់ក្ដាម។

គ្រំ(Shell)ត្រូវគេប្រមូលបានតែក្នុងបរិមាណតិចតួចប៉ុណ្ណោះ គឺសម្រាប់តែប្រើប្រាស់ក្នុង តំបន់។ អ័រស្ទ័រ(Oyster) ត្រូវបានចាប់យកដោយសេរីពីឬសកោងកាង។ Bloodclams (Anadara) និងខ្យងផ្សេងៗទៀតត្រូវបានប្រមូលជាច្រើនពីតំបន់ភក់នៅពីមុខព្រៃកោងកាង។ មឹក(Squids)ត្រូវបានចាប់យកដោយប្រើអួន និងមងកន្ត្រៃ និងលក់ភាគច្រើនក្នុងរូបភាពស្ងួត។

### ឆ. ផលិតផលត្រីចិញ្ចឹម និងអំបិល

តំបន់ព្រៃកោងកាងមួយចំនួនត្រូវបានកាប់ឆ្ការសំអាតដើម្បីធ្វើសិប្បកម្មបង្គារ ផលិតផលត្រី ខ្យង និងអំបិល។ តាមការអនុវត្តជាក់ស្តែងមានតែផលិតកម្មខ្នាតតូចសម្រាប់តែការប្រើប្រាស់ក្នុងតំបន់ទេ លើកលែងតែបង្គារត្រូវបាននាំចេញក្នុងពេលខ្លះៗ។

## ២. តម្លៃប្រើប្រាស់មិនផ្ទាល់

### ក.ផលចំណេញពីជីវចម្រុះ

ជីវចម្រុះមានរួមបញ្ចូលជម្រើសផ្សេងៗ ដែលក្នុងនោះមាន តម្លៃប្រើប្រាស់ផ្ទាល់ និងមិនផ្ទាល់ និងតម្លៃជីវិតរស់នៅ។ កោះកាពីក នៅខេត្តកោះកុងត្រូវបានគេចាត់ទុកថាមាន តម្លៃជីវចម្រុះខ្ពស់។ កន្លែងនេះ ជាតំណាងដ៏ល្អវិសេសនៃប្រព័ន្ធព្រៃកោងកាង ដែលមានព្រៃ (Melaleuca) នៅជុះពីជួរក្រោយបើប្រៀបធៀបទៅនឹងកន្លែងផ្សេងៗទៀត។ ព្រៃនេះក៏ជាកន្លែងដ៏សំខាន់ជាអន្តរជាតិសម្រាប់សត្វបក្សីធ្វើអន្តោប្រវេសន៍មកជ្រកកោន។

មានការលំបាកក្នុងការប៉ាន់ស្មានអត្ថប្រយោជន៍ជីវចម្រុះ ដោយសារមួយផ្នែកធំនៃអត្ថប្រយោជន៍នេះស្ថិតនៅក្នុងប្រភេទដើមឈើដែលមិនទាន់រកឃើញនូវអត្ថប្រយោជន៍នៃការប្រើប្រាស់របស់វា ហើយ

ដែលអាចមានសក្តានុពលតម្លៃអាជីវកម្ម ដូចជាតម្លៃក្នុងវេជ្ជសាស្ត្រ និងកសិកម្ម។ ជីវចម្រុះនៃព្រៃកោងកាងអាចមានតួនាទីដ៏សំខាន់ក្នុងការពង្រឹងតួនាទីនិយ័តកម្ម ដូចជា នៅក្នុងបម្រែបម្រួលចម្រុះភាពនៃពូជដើមឈើទាំងឡាយអាចជះឥទ្ធិពលទៅលើថាតើតួនាទីសេវាកម្ម និង ការការពារល្អរបស់វាយ៉ាងដូចម្តេចខ្លះ និងក្នុងករណីខ្លះរហូតដល់យើងអាចប្រើប្រាស់ជាប្រយោជន៍បាន។

### ខ. ការទប់ទល់នឹងព្យុះ ខ្យល់

តំបន់ទ្រនាប់ការពារដែលផ្តត់ផ្គង់ដោយខ្សែព្រំព្រៃកោងកាងត្រូវបានគេទទួលស្គាល់ជាការជួយការពារទប់ទល់ប្រឆាំងនឹងផលប៉ះពាល់អន្តរាយន៍ទាំងឡាយពីព្យុះ និងពីទឹកជោរធំៗ។ ភូមិនៅតាមឆ្នេរមួយចំនួនកម្របានទទួលរងផលប៉ះពាល់ពីរលក និងព្យុះធំៗណាស់ ពីព្រោះពួកគេត្រូវបានការពារយ៉ាងល្អដោយខ្សែព្រៃកោងកាងតាមឆ្នេរសមុទ្រ។

### គ. ការបញ្ចូល និងការបញ្ចេញទឹកក្រោមដី

ការបញ្ចូលទឹកក្រោមដី សំដៅដល់តួនាទីរបស់ព្រៃកោងកាងក្នុងការផ្លាស់ប្តូរ និងផ្គត់ផ្គង់ស្រទាប់ទឹកក្រោមថ្ម។ ការបញ្ចេញទឹកក្រោមដី សំដៅដល់តួនាទីរបស់ព្រៃកោងកាងក្នុងការបញ្ចេញទឹកពីក្រោមថ្ម។ ការណ៍នេះអាចជាផលប្រយោជន៍សុវត្ថិភាពដ៏សំខាន់ក្នុងការបង្ការកុំឲ្យមានជន់លិចពេលមានទឹកជំនន់ឡើងខ្ពស់។

### ឃ. ស្ថិរភាពច្រាំងសមុទ្រ និងការគ្រប់គ្រងការខូចរិចរិល

ព្រៃកោងកាងជួយការពារខ្សែឆ្នេរមិនឲ្យខូចរិចរិល អញ្ចឹងក៏ជួយបង្ការមិនឲ្យមានការខាតបាត់បង់ដី និងទ្រព្យសម្បត្តិកសិកម្ម ព្រមទាំងផលិតភាពនៃដីកសិកម្មផងដែរ។

### ង. ការរក្សាទុកភាកសំណល់ និងចំណីអាហារ

លទ្ធភាពរបស់ព្រៃកោងកាងដែលអាចរក្សាកាកសំណល់ និងចំណីអាហារបាន អាចមានឥទ្ធិពលសំខាន់ពីរយ៉ាង។ ទី១ វាអាចធ្វើឲ្យមានការកើនឡើងនូវផ្ទៃដីអាចធ្វើកសិកម្មបាន និងទី២ វាអាចការពារបាននូវសកម្មភាពសេដ្ឋកិច្ច តាមបណ្តោយដងអូរ និងការពារដីពីកាកសំណល់នេះ។

លើសពីនេះ ចំណីអាហារសរីរាង្គ ដែលក្នុងនោះមានរួមបញ្ចូលអ្វីៗដែលចេញពីកាកសំណល់មនុស្ស និងសត្វ ត្រូវបានព្រៃកោងកាងស្រូបយកទុកជាមួយនឹងកាកសំណល់ផ្សេងៗទៀត។

សកម្មភាពរបស់ព្រៃកោងកាងក្នុងការរក្សាទុកកាកសំណល់ និងចំណីអាហារនេះ ក៏មានជាប់ពាក់ពន្ធទៅនឹងតួនាទីនៃការថែទាំគុណភាពទឹកផ្សេងៗ ដូចជាការបំលែងចំណីអាហារ ការរក្សានូវការទប់ស្កាត់ជាតិពុលដែលបង្កើតឡើងដោយរុក្ខជាតិ។

### ច. ស្ថិរភាពអាកាសធាតុក្នុងតំបន់តូចៗ

ខួបទូទៅនៃជលផល ចំណីអាហារ និងធនធាន និងលំហូរថាមពលដែលបានពីព្រៃកោងកាង អាចជួយឲ្យមានស្ថិរភាពលក្ខខ័ណ្ឌអាកាសធាតុក្នុងតំបន់ ជាពិសេសសំណើម និងកំដៅ។ ការណ៍នេះ នាំឲ្យមានអានុភាពទៅលើសកម្មភាពកសិកម្ម និង មូលដ្ឋានធនធាន និងក៏ដូចជាទៅលើស្ថិរភាពប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងរុក្ខជាតិកោងកាងផ្ទាល់ដែរ។

នៅឆ្នាំ២០០១ លោក De Lopez et Al. បានធ្វើការប៉ាន់ស្មានអត្ថប្រយោជន៍ប្រើប្រាស់ផ្ទាល់ និងមិនផ្ទាល់នៃព្រៃកោងកាង ក្នុងរង្វង់ ៥០០ដុល្លារ/ហត/ឆ្នាំ ដែលរួមផ្សំដោយ

| | |
|---|---|
| ការប្រើប្រាស់ក្នុងតំបន់ | : ៣៥៥ ដុល្លារ |
| ការពារទប់នឹងព្យុះ | : ៣២ ដុល្លារ |
| ការពារការខូចខាតឆ្នេរ | : ១២២ ដុល្លារ |
| ការទាញយកកាបោន | : ២ ដុល្លារ |

### ៣. តម្លៃប្រើប្រាស់ផ្សេងទៀត

ការរីកចម្រើនខាងវិស័យដឹកជញ្ជូនតាមផ្លូវអាកាស បានជួយសម្រួលដល់ការធ្វើដំណើរទៅកាន់ទីកន្លែងឆ្ងាយៗ។ ជាមួយគ្នានេះ ការរីកចម្រើនខាងវិស័យទូរគមនាគមន៍ក៏រិតតែធ្វើឲ្យមានការកើនឡើងនូវចំណេះដឹងអំពីស្ថានភាពទីកន្លែង ស្រុកទេស និងអារ្យធម៌របស់ប្រទេសដទៃ។ កត្តាទាំងអស់នេះបានជំរុញឲ្យអ្នកទេសចរនៅក្នុងពិភពលោក រិតតែចង់ធ្វើដំណើរទៅមើលជាក់ស្តែងដល់ទីកន្លែងដែលមានលក្ខណៈពិសេសៗ ហើយនឹងបើអាចជៀសវាងនូវកន្លែងរម្មណីយដ្ឋានទេសចរណ៍ណាដែលមានមនុស្សច្រើនកកកុញ។ ជាមួយនឹងចំណូលចិត្តចង់ឃើញកន្លែងពិសេសថ្មីៗទាំងនោះ ពួកអ្នកទេសចរក៏មានទឹកចិត្តធ្វើយ៉ាងណាកុំឲ្យកន្លែងដែលគាត់ធ្លាប់បានទៅមើលកំសាន្តនោះបាក់បែកខូចខាត ហើយព្រមទាំងបំផ្លាញវប្បធម៌របស់ប្រជាពលរដ្ឋដែលរស់នៅកន្លែងនោះផងដែរ។ ដំណើរកម្សាន្តតាមរបៀបនេះ ត្រូវបានគេឲ្យឈ្មោះថាអេកូទេសចរណ៍ ឬទេសចរណ៍ធម្មជាតិ។

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ទេសចរណ៍ធម្មជាតិមានប្រជាប្រិយភាពតែក្នុងតំបន់ប្រទេសជឿនលឿន ដូចជាអាមេរិចខាងជើង អឺរ៉ុប អូស្ត្រាលី និងជប៉ុនប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅទសវត្សរ៍ចុងក្រោយនេះ ទេសចរណ៍ធម្មជាតិក៏បានរីកសាយនៅព្រះរាជាណាចក្រកម្ពុជាផងដែរ គឺក្រោយពេលមានការរៀបចំឲ្យកាន់តែប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធទាំងឡាយ។

ក្រៅពីប្រាសាទប្រវត្តិសាស្ត្រទាំងឡាយនៅតំបន់អង្គរ ភូមិភាគតាមតំបន់ឆ្នេរសមុទ្រ ក៏បានផ្តល់នូវទេសនីយភាពយ៉ាងប្រណីតជាមួយនឹងព្រៃកោងកាងដែលជាសម្បត្តិនៃទេសចរណ៍ធម្មជាតិផងដែរ។

ឧទ្យានពាមក្រសោបនៅខេត្តកោះកុង គឺជាកន្លែងតែមួយគត់ដែលផ្តល់ឱកាសដល់អ្នកទេសចរធម្មជាតិអាចទៅមើលកំសាន្តព្រៃកោងកាង។ ផលវិជ្ជមានទាំងឡាយនៃទេសចរណ៍បែបនេះមានដូចជាៈ

–ណែនាំឲ្យអ្នកទេសចរយល់ដឹងពីវត្តមាននៃព្រៃឈើ ដើមឈើ និងសត្វព្រៃគ្រប់យ៉ាង។ ការយល់នេះនឹងនាំឲ្យអ្នកទេសចរមានចិត្តចេះចូលរួមយ៉ាងសកម្មក្នុងការថែរក្សា និងការពារព្រៃកោងកាង។

–ផ្តល់ការងារដល់ប្រជាពលរដ្ឋមូលដ្ឋាន

–បង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមូលដ្ឋានពីការធ្វើជំនួញជួញដូរ ដូចជាការលក់វត្ថុអនុស្សាវរីយ៍ សណ្ឋាគារ ភោជនីយដ្ឋាន។ល។

–ផ្តល់ប្រាក់ចំណូលដល់អ្នកគ្រប់គ្រងឧទ្យានដែលតែងតែខ្វះខាតជានិច្ចនូវថវិការដើម្បីយកទៅបម្រើដល់ការគ្រប់គ្រងព្រៃកោងកាងឲ្យកាន់តែប្រសើរឡើង។

ជាការពិតណាស់ជាមួយនឹងផលវិជ្ជមានទាំងនេះ ក៏មានផលអវិជ្ជមានខ្លះៗផងដែរ ពីព្រោះថាដើម្បីអភិវឌ្ឍ អ្នកវិនិយោគត្រូវកាប់ឆ្ការព្រៃកោងកាងខ្លះដើម្បីធ្វើជាសណ្ឋាគារ ផ្លូវ ចំណតរថយន្ត និងកន្លែងលក់ដូរផ្សេងៗសម្រាប់ផ្តល់សេវាកម្មដល់អ្នកទេសចរ។ អ្នកគ្រប់គ្រងឧទ្យានត្រូវតែប្រឈមជាមួយនឹងការសម្រេចចិត្តថាតើគួរចំណាយផ្ទៃដីព្រៃប៉ុន្មានហិចតា និងនៅកន្លែងណាដើម្បីអភិវឌ្ឍ ក៏ដូចជាថាតើគួររក្សាទុកប៉ុន្មានហិចតា និងកន្លែងណាដើម្បីការពារ និងថែទាំឲ្យនៅមានលក្ខណៈជាធម្មជាតិ។

## V. ការគំរាមកំហែងលើព្រៃកោងកាង

បើទោះបីជាព្រៃកោងកាងត្រូវបានគេចាត់ទុកថាមានអត្ថប្រយោជន៍ជីវចម្រុះ សង្គម និងសេដ្ឋកិច្ចសំខាន់ណាស់ចំពោះប្រជាពលរដ្ឋតំបន់ឆ្នេរក៏ដោយ ក៏ការបិតបេររបស់វានៅតែបន្តជួបប្រទះនឹងការគំរាមកំហែងតាំងតែពីអតីតកាលរហូតដល់បច្ចុប្បន្នកាល។ កត្តាមួយចំនួនមានដូចខាងក្រោមដែលធ្វើឲ្យមានការថយចុះនូវទំហំព្រៃកោងកាង ។

### ក.តម្រូវការលើការដាំដុះ និងការកាប់ឈើដើម្បីចិញ្ចឹមជីវិត

ចំនួនប្រជាពលរដ្ឋនៅតាមតំបន់ឆ្នេរ បានកើនឡើងយ៉ាងលឿន ពី៤៣២,០០០ នៅឆ្នាំ១៩៨១ ដល់៩៦០,០០០ នៅឆ្នាំ២០០៨ មូលហេតុចម្បងបំផុតដោយសារចំណូលស្រុក។ និន្នាការនេះ គឺដោយសារកត្តាសេដ្ឋកិច្ច ដែលទាក់ទាញដោយសក្តានុពលខ្ពស់នៃចំណូលដែលបានពីការនេសាទ និងផលិតកម្មធ្យូង ដែលបានចាប់ផ្តើមមុនចុងទស្សវត្សឆ្នាំ៨០ ពីព្រោះជាតំបន់ដែលមានប្រជាពលរដ្ឋ និងការរុករកធនធាននៅតិចតួចនៅឡើយ។

នៅតំបន់ខេត្តកោះកុង ឧទាហរណ៍ អ្នកចំណូលស្រុក មានមធ្យមភាគខ្ពស់ (៧៦%) បានចូលក្នុងអំឡុងពេល ១៩៨០–១៩៩៥។ ការហូរចូលខ្លាំងបំផុតនៅចន្លោះពេល ១៩៨៥–១៩៩៥។ មុនឆ្នាំ១៩៨០ ការហូរចូលមានចំនួនតិច និងចាប់ពី ឆ្នាំ១៩៩៥ លំហូរនេះមានការថយចុះ។

នៅពេលប្រជាពលរដ្ឋនៅតំបន់នេះកើនឡើង តម្រូវការលើផលិតផលកោងកាងសម្រាប់សាងសង់(ផ្ទះស្នាក់នៅ កំពង់ផែ និងសម្ភារៈសំណង់ផ្សេងៗ ថាមពលពីឈើ (អុស ធ្យូង) និងរបរចិញ្ចឹមជីវិត (អុស ធ្យូង សសរ ) ក៏បានកើនឡើងផងដែរ។

នៅឆ្នាំ១៩៩២ មានតួលេខប៉ាន់ស្មានដែលក្នុងនោះមានឡធ្យូងច្រើនជាង៣០០ឡដែលបានផលិតធ្យូងលើសពី២៤,០០០តោន ដែល៩៤%នៃផលិតផលនេះបាននាំចេញទៅប្រទេសថៃ ហើយត្រូវការបរិមាណឈើកោងកាងតាមការប៉ាន់ស្មានប្រហែល១០០,០០០តោនដើម្បីផលិតធ្យូងក្នុងបរិមាណនេះ។ នៅឆ្នាំ១៩៩៤ មានគណៈកម្មការប្រឆាំងឡធ្យូងមួយត្រូវបានបង្កើតឡើងដោយអាជ្ញាធរតំបន់ក្នុងគោលបំណងត្រួតពិនិត្យសកម្មភាពផលិតធ្យូងមិនស្របច្បាប់។ គណៈកម្មការនេះមានដំណើរការតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ដោយសារការខ្វះធនធាន។ ក្នុងពេលនោះ មានការកើនឡើងនូវចំនួនឡតូចៗត្រូវបានបង្កើតឡើងដោយបានផ្លាស់ទីតាំងនចូលទៅក្នុងព្រៃកាន់តែជ្រៅទៅៗដើម្បីគេចពីការរកឃើញ។

ថ្វីបើការនាំចេញធ្យូងត្រូវចាត់ថាខុសច្បាប់ចាប់ពីពាក់កណ្តាលឆ្នាំ១៩៩៤ក៏ដោយ ក៏ចំនួនឡដុតធ្យូងនៅតែមានការកើនឡើង។ ការណ៍នេះជំរុញឲ្យមានការប៉ុនប៉ងរបស់គណៈកម្មការប្រឆាំងនឹងឡដុតធ្យូងជាលើកទី២ នៅខែកក្កដាឆ្នាំ១៩៩៦ដើម្បីបញ្ឈប់ផលិតកម្មធ្យូង។ នៅខែមករា ឆ្នាំ១៩៩៧ គណៈកម្មការនេះ ជាមួយនឹងជំនួយរបស់អាជ្ញាធរ នគរបាលមូលដ្ឋាន និងកងទាហ៊ានបានកំទេចចោលឡដុតធ្យូងនៅតំបន់នេះស្ទើរតែទាំងអស់ ដែលមានប្រហែល១០០០ឡ។ ដោយផ្អែកតាមការបិទឡដុតធ្យូងទាំងនេះ គោលបំណងរបស់រដ្ឋាភិបាល គឺធ្វើការគ្រប់គ្រងឡើងវិញលើព្រៃកោងកាង និងបន្ទាប់មកធ្វើនិយ័តកម្ម និងធ្វើឲ្យវិស័យផលិតធ្យូងនេះឲ្យស្របច្បាប់វិញ។ នេះដោយសារមានការយល់ដឹងថាប្រជាពលរដ្ឋក្នុងតំបន់ ត្រូវការធ្យូងពីព្រោះពួកគេមិនអាចទិញប្រេងឥន្ធនៈ។

### ខ.ការទន្ទ្រានយកដីដើម្បីធ្វើសិប្បកម្មបង្គារ និងក្តាម

ក្នុងអំឡុងឆ្នាំ១៩៩៥ ផ្ទៃដីព្រៃកោងកាង ៦៥ហាត នៅព្រែកតាស៊ុំ ត្រូវបានគេទិញ និងធ្វើឯកជនភាវូបនីយកម្ម។ មួយភាគនៃផ្ទៃដីនេះ ត្រូវបានសំអាតដើម្បីធ្វើសិប្បកម្មបង្គារ និងក្តាម និងមួយភាគទៀតត្រូវបានជីកធ្វើជាព្រែកដើម្បីនាំបង្គារដោយខុសច្បាប់ គឺពីលំហូរសមុទ្រធម្មជាតិ ហើយបន្ទាប់មកចាប់វាក្នុងពេលទឹកស្រក។

ក្នុងអំឡុងឆ្នាំ១៩៩៧ ផ្ទៃដីព្រៃកោងកាង ៤៧ហាត នៅកោះខ្យង ត្រូវបានអនុញ្ញាតិឲ្យបង្កើតជាកសិដ្ឋានចិញ្ចឹមក្តាម។ នេះជាលទ្ធផលក្នុងការការពារដោយក្រុមអ្នកភូមិដែលមិនអាចចូលទៅក្នុងតំបន់ចាប់ក្តាម និងខ្យងដូចកាលពីមុន។

នៅឆ្នាំ១៩៩៩ ផ្ទៃដីព្រៃកោងកាង ១៥ហាតត្រូវបានទន្រ្ទាននៅឯតំបន់ចុងជ្រោយដោយប្រជាពលរដ្ឋក្នុងតំបន់ និងមួយចំនួនមកពីក្រៅ។ ប្រជាពលរដ្ឋត្រូវបានគេជួលឲ្យជីកព្រែកដើម្បីឲ្យបង្គារហូរចូលនៅពេលទឹកឡើង និងចាប់វានៅពេលទឹកស្រក។

នៅឆ្នាំ២០០២ ផ្ទៃដីព្រៃកោងកាងកាន់តែធំត្រូវបានបំផ្លាញដើម្បីធ្វើការសាងសង់ផ្ទះ កន្លែងចិញ្ចឹមបង្គារ ដូចជា

២៥ហាត នៅព្រែកកូនគុក

៧ហាត នៅជុំវិញទន្លេអូជ្រៅ

១៥ហាត នៅព្រែកតាសុប

ការប្រែក្លាយព្រៃកោងកាងទៅជាកន្លែងកសិដ្ឋានចិញ្ចឹមបង្គារ បានបង្ករផលប៉ះពាល់អវិជ្ជមានទៅលើប្រជាពលរដ្ឋ និងលើជីវចម្រុះតាមតំបន់ឆ្នេរ។ ជារួម នៅចុងឆ្នាំ១៩៩៤ ផ្ទៃដីព្រៃកោងកាង ១២៤០ហាត នៅកោះកុងត្រូវបានប្រែក្លាយសម្រាប់គោលបំណងនេះ។

គឺមានអត្ថប្រយោជន៍ណាស់ក្នុងការកត់សំគាល់ថា បន្ទាប់ពីឆ្នាំ២០០០មក ការចិញ្ចឹមបង្គារស្ទើរតែទាំងអស់ត្រូវបានបិទ ដោយសារអ្នកចិញ្ចឹមបានទទួលរងការខាតបង់យ៉ាងខ្លាំង។ ជាមួយគ្នានេះដែរ គេប៉ាន់ស្មានថា ផ្ទៃដីព្រៃកោងកាង ពី៣៥០០ ទៅ៤០០០ហាត នៅខេត្តកំពត និងខេត្តកែប ត្រូវបានគេប្រែក្លាយជាកសិដ្ឋានផលិតអំបិល។

### គ.ការទន្ទ្រានយកដីដើម្បីកេងចំណេញ

តំបន់ព្រៃកោងកាងក៏ត្រូវបានទន្រ្ទានយកខុសច្បាប់ និងលក់ដើម្បីអភិវឌ្ឍ។ ប្រជាពលរដ្ឋដែលមកពីក្រៅតំបន់ ថ្មីៗនេះ បានទិញដីពីអ្នកភូមិមួយចំនួនតាមតម្លៃដ៏ទាប ពី៣០ដុល្លារ ទៅ៥០ដុល្លារ/ហាត ហើយដែលទាមទារព្រៃដោយខុសច្បាប់។

តំបន់មួយចំនួនតាមបណ្តោយឆ្នេរទទួលរងនូវការទាមទារ តវ៉ា ទុកជាផ្នែកមួយនៃការកេងចំណេញលើដី។ ជាពិសេសសង្កេតឃើញនៅជុំវិញតំបន់ក្បែរទីប្រជុំជននៃខេត្តព្រះសីហនុ និងខេត្តកែប ឬក៏តំបន់ដែលទើបអភិវឌ្ឍថ្មីៗ ដូចជានៅក្បែរមូលដ្ឋាននាវាឆ្នេររាម និងកំពង់ផែឧកញ៉ា ម៉ុង រិទ្ធី នៅកែវផុស។ ជាទូទៅ ការតវ៉ាទាមទារដីទាំងនេះច្រើនមានទំហំតូចៗ។ គោលបំណងដំបូងគឺពង្រីកផ្ទៃដីឲ្យទៅជាដីឯកជន។

គណៈកម្មការគ្រប់គ្រង និងវាយតម្លៃ ចំពោះការបង្ក្រាបការទន្រ្ទានយកដីព្រៃ   កោងកាង និងការទាមទារដីតំបន់ឆ្នេរ ត្រូវបានបង្កើតឡើងដោយប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា (ប្រកាសលេខ២៨ ស.ស.រ ឆ្នាំ២០០៥)។ កាតព្វកិច្ច និងភារកិច្ចរបស់គណៈកម្មការ គឺចាត់វិធានការបញ្ឈប់សកម្មភាពទន្រ្ទានយកដី បង្ខំឲ្យប្រគល់ដីដែលបានទន្រ្ទាន និងទាមទារដីមកវិញ បញ្ជាឲ្យអ្នកធ្វើខុសដាំឈើកោងកាងសារជាថ្មីដើម្បីជំនួសឈើកោងកាងដែលបានសំអាត និងរំលំ។

### ឃ.ការប្រែក្លាយតំបន់ព្រៃកោងកាងឲ្យនៅជាដីចំការកសិកម្ម

ថ្វីត្បិតតែមិនអាចដឹងចំនួនហិចតាពិតប្រាកដ ប៉ុន្តែក៏ត្រូវបានដឹងថា ព្រៃកោងកាងរាប់រយហិចតា នៅព្រែកបាញ់ជ្រូក នៅឆ្នាំ១៩៩៥ និងនៅម៉ាអ៊ូ នៅឆ្នាំ១៩៩៧ ត្រូវបានកាត់ និងសំអាតសម្រាប់ធ្វើចំការដូង ខ្នុរ និងស្វាយ ក៏ដូចជាសម្រាប់ធ្វើស្រែ។

**ខ.ប្រជាពលរដ្ឋក្នុងតំបន់ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ**

ប្រជាពលរដ្ឋក្នុងតំបន់មួយចំនួនបានទន្ទ្រានយកដីព្រៃកោងកាង ហើយលក់ទៅឲ្យអ្នកផ្សេង។ ប្រជាពលរដ្ឋក្រីក្រដែលមកពីក្រៅតំបន់មករស់នៅ ក៏បំផ្លិចបំផ្លាញព្រៃកោងកាងដែរ។ ពួកគាត់បានធ្វើការជាកម្មករសាងសង់ទំនប់ទឹក និងជីកព្រែកទាំងឡាយ។ ការបង់ថ្លៃពលកម្មទាបណាស់ ឧទាហរណ៍សម្រាប់ផ្ទៃក្រឡា៣ម៉ែតការ៉េ ទទួលបានតែ៧០០០រៀលប៉ុណ្ណោះ។

លើសពីនេះទៀត មានទំនាស់គ្នារវាងអ្នកនេសាទទឹករាក់ និងទឹកជ្រៅ ។ អ្នកនេសាទកាន់តែច្រើនគ្នាប្រើប្រាស់វិធីសាស្ត្រកាន់តែទំនើប និងឧបករណ៍ខុសច្បាប់ដើម្បីចាប់ត្រី។ ការកើនឡើងនូវចំនួនទូកម៉ាស៊ីនដែលប្រើប្រាស់ដោយអ្នកនេសាទដែលនេសាទនៅក្នុងទឹកដែលមាជម្រៅតិចជាង២០មត្រូវដែលច្បាប់នេសាទបានហាមឃាត់។ សកម្មភាពរបស់អ្នកនេសាទទឹកជ្រៅ ធ្វើឲ្យអ្នកនេសាទទឹករាក់ខឹងដែលធ្វើឲ្យកើតមានជាទូទៅនូវសោកនាដកម្មដែលនៅក្នុងនោះម្នាក់ៗគិតតែស្វែងរកធ្វើយ៉ាងម៉េចឲ្យបានផលចំណេញកាន់តែច្រើនតាមតែខ្លួនអាចធ្វើទៅបាន គឺធ្វើឲ្យខូចខាតអន្តរាយន៍ដល់ធនធានធម្មជាតិដែលក្នុងករណីនេះមានត្រី និងព្រៃកោងកាង។ ជាលទ្ធផល នៅតំបន់ជិតឆ្នេរ ជាទូទៅមានការនេសាទលើសលុបពេក ហើយធ្វើឲ្យការការពារព្រៃកោងកាងមិនត្រូវបានគេគិតទេ។

តួនាទីភារកិច្ចគ្រប់គ្រងធនធានធម្មជាតិស្ថិតក្នុងការទទួលខុសត្រូវរបស់ស្ថាប័នជំនាញដូចជារដ្ឋបាលជលផល និងក្រសួងបរិស្ថាន។ ប៉ុន្តែ កាលពីមុនអ្នកជំនាញ មិនមានសម្មត្ថភាពលទ្ធភាពសមស្រប និងគ្រប់គ្រាន់ដើម្បីការពារ និងទប់ទល់នឹងប្រតិបត្តិការខុសច្បាប់នោះទេ។ ម្យ៉ាងទៀតមិនមានសហប្រតិបត្តិការរវាងស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន។ ហេតុដូច្នេះហើយការគ្រប់គ្រងព្រៃកោងកាងនៅមានភាពខ្វះចន្លោះ។

## VI. ហេតុដូចម្តេចបានជាបញ្ហាគំរាមកំហែងនេះកើតឡើង

មានកត្តាជាច្រើនដែលធ្វើឲ្យមានបញ្ហាពុំរៃចំពោះព្រៃកោងកាង:

**ក.តម្រូវការលើអុស ធ្យូង និងផលិតផលព្រៃឈើផ្សេងទៀត**

ប្រជាពលរដ្ឋតំបន់ឆ្នេរក្រីក្រតែងតែត្រូវការអុស និងធ្យូងសម្រាប់ការចំអិនអាហារជារៀងរាល់ថ្ងៃពីព្រោះពួកគាត់មិនអាចមានលទ្ធភាពបង់ថ្លៃឧស្ម័ន។ ក្នុងពេលជាមួយគ្នាដែរពួកគាត់ក៏ត្រូវការចំណូលតិចតួចបន្ថែមទៀតពីការលក់ផលិតផលព្រៃឈើដែលប្រមូលបាននៅក្នុង និងជុំវិញតំបន់ព្រៃកោងកាង។

### ខ.កង្វះខាតការសិក្សា និងការដាក់ពិន័យ

មានកង្វះខាតការសិក្សា ការវាយតម្លៃផលប៉ះពាល់ ការត្រួតពិនិត្យឡើងវិញលើតំបន់ព្រៃកោងកាង ដែលបានអនុញ្ញាតិ ឲ្យប្រើប្រាស់តាមរបៀបផ្សេងៗ ដូចជាវារីវប្បកម្មជាដើម។ វារីវប្បកម្មដែលតាមរយៈការពង្រីកទំហំទីតាំង បានជួយដល់អ្នកមានទ្រព្យ និងអ្នកមានអំណាចទន្ទ្រានយកព្រៃកោងកាង ក៏ដូចជាការប្រើប្រាស់ដីសម្រាប់ការតាំងភូមិលំនៅ។ ម្យ៉ាងទៀតស្ថាប័នគ្រប់គ្រងគ្រាន់តែយកចិត្តទុកដាក់តែលើតំបន់ដែលត្រូវបានបំផ្លិចបំផ្លាញប៉ុណ្ណោះ ប៉ុន្តែមិនមានសកម្មភាពដ៏មានប្រសិទ្ធភាពណាត្រូវបានយកមកប្រើដើម្បីប្រឆាំងនឹងការប្រព្រឹត្តបទល្មើសដែលនាំទៅរកការបន្តការបំផ្លិចបំផ្លាញនៃព្រៃកោងកាងដែលនៅក្រៅតំបន់ការពារ និងនៅសួនឧទ្យានជាតិនោះទេ។

### គ.កង្វះការយល់ដឹង និងសម្បជញ្ញៈរបស់សហគមន៍មូលដ្ឋាន

ប្រជាពលរដ្ឋភាគច្រើននៃសហគមន៍មូលដ្ឋានមិនបានយល់ច្បាស់អំពីផលប៉ះពាល់នៃការបាត់បង់ព្រៃកោងកាងទេ។ ពួកគាត់គ្រាន់តែសុខចិត្តធ្វើជាកម្មករស៊ីឈ្នួលឲ្យគេជាមួយនឹងកម្រៃដ៏ស្តួចស្តើងនៅក្នុងការរកចំណូលដើម្បីចិញ្ចឹមគ្រួសាររបស់ខ្លួនតែប៉ុណ្ណោះ។ ក៏ប៉ុន្តែបន្ទាប់ពីជួបប្រទះការលំបាកដោយសារតែការបាត់បង់តំបន់ព្រៃកោងកាង និងតំបន់ត្រីមក ទើបសម្បជញ្ញៈរបស់ពួកគាត់មានការកើនឡើង និងចាប់ផ្តើមត្អូញត្អែរប្តឹងតវ៉ា។

ពត៌មាន និងការផ្តល់ដំណឹងអំពីការគ្រប់គ្រង និងការពារធនធានធម្មជាតិ ជាពិសេសការគ្រប់គ្រងព្រៃកោងកាង ផលប្រយោជន៍របស់វា និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន មិនទាន់បានផ្សព្វផ្សាយបានគ្រប់គ្រាន់នៅឡើយទេ ហេតុដូច្នេះហើយ នៅមានការខ្វះខាតដ៏ធ្ងន់ធ្ងរនៃការចូលរួមចំណែកពីសំណាក់សហគមន៍មូលដ្ឋាននៅក្នុងការគ្រប់គ្រង់ព្រៃកោងកាង ។

### ឃ.ការខិតខំប្រឹងប្រែងនៅក្នុងការកាត់បន្ថយការបំផ្លិចបំផ្លាញព្រៃកោងកាង

១. ការប៉ុនប៉ងនៅក្នុងការដោះស្រាយការបំផ្លិចបំផ្លាញព្រៃកោងកាង ត្រូវបានធ្វើឡើងដោយស្ថាប័នជំនាញ និងដោយសហគមន៍មូលដ្ឋាន ប៉ុន្តែដំណោះស្រាយមានភាពយឺតយ៉ាវ និងមិនបានជោគជ័យ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី យើងសង្កេតឃើញថានៅពេលដែលសហគមន៍មូលដ្ឋានចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញ ភ័ពសំណាងជោគជ័យបានកាន់តែប្រសើរ។

២. ស្ថាប័នជំនាញដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងព្រៃកោងកាង គឺការិយាល័យជលផល និងបរិស្ថាន។ នៅពេលទទួលបានពត៌មានថាមានការបំផ្លិចបំផ្លាញព្រៃកោងកាងកើតមាន អាជ្ញាធរមានសមត្ថកិច្ចនឹងបញ្ជូនបុគ្គលិករបស់ខ្លួនឲ្យទៅធ្វើអធិការកិច្ចភ្លាមៗ។ ជួនកាល អធិការមិនបានឃើញ ឬក៏មិនបាននិយាយជាមួយជនល្មើសទេ គឺគ្រាន់តែធ្វើរបាយការណ៏តែប៉ុណ្ណោះ។ ក្នុងករណីបានឃើញជនល្មើសនៅនឹងកន្លែង អធិការនឹងឲ្យជននោះចុះហត្ថលេខាលើកិច្ចសន្យាឈប់ប្រព្រឹត្តបទល្មើសដដែលនេះទៀត។ ជួនកាលជនល្មើសត្រូវបានព្រមានតែតាមរយៈពាក្យពេជន៍ប៉ុណ្ណោះ។ បន្ទាប់ពីហ្នឹងមកក៏គ្មានការតាមដានពិនិត្យបន្តទៀតដែរ និងដោយសារភាពចាំបាច់នៅក្នុងការចិញ្ចឹមជីវិតរបស់ពួកគេ ជន

ល្មើសនឹងប្រព្រឹត្តសកម្មភាពខុសច្បាប់ម្តងហើយម្តងទៀត។ ហេតុដូច្នេះ ស្ថានភាពនេះមិនមានប្រសិទ្ធភាពពីព្រោះផ្ទៃក្រឡាកាន់តែធំត្រូវបានបំផ្លាញ។

ម្យ៉ាងទៀត នៅក្នុងតំបន់ដែលគ្រប់គ្រងដោយសហគមន៍មូលដ្ឋានសហការជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋានដើម្បីការពារ និងបញ្ឈប់សកម្មភាពបំផ្លិចបំផ្លាញ លទ្ធផលដែលទទួលបានមានប្រសិទ្ធភាព និងជោគជ័យជាង។ ប្រសិនបើប្រជាពលរដ្ឋឃើញអ្នកណាម្នាក់កាប់ព្រៃកោងកាងពួកគាត់អាចបញ្ជូនពត៌មានជាបន្ទាន់ដល់ស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន និងដល់ក្រុមការងារអាជ្ញាធរគ្រប់គ្រងធនធានខេត្ត និងតំបន់ឆ្នេរ ដើម្បីរៀបចំសំណុំរឿងប្រឆាំងនឹងជនល្មើស។ បន្ទាប់មកអាជ្ញាធរបានធ្វើការកោះហៅជនល្មើស និងឲ្យចុះហត្ថលេខាលើកិច្ចសន្យានៅទល់មុខតំណាងសហគមន៍ដើម្បីបញ្ឈប់សកម្មភាពនៅថ្ងៃក្រោយទៀត។

ដោយជឿជាក់ថា ការចូលរួមរបស់សហគមន៍គឺជាគន្លឹះឲ្យជោគជ័យនៅក្នុងការការពារព្រៃកោងកាង ស្ថាប័នជំនាញបានដាក់ចេញនូវកាប្រឹងប្រែងរបស់ខ្លួនឲ្យកាន់តែខ្លាំងនៅក្នុងការបង្កើតសហគមន៍ឲ្យបានកាន់តែច្រើនដើម្បីការពារព្រៃកោងកាង និងត្រី។ ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៩ មានសហគមន៍នេសាទទាំងអស់៤៦៩នៅទូទាំងប្រទេសកម្ពុជា ដែលមាន១២៦,៤៩០គ្រួសារ ផ្សំចេញពីមនុស្សចំនួន ២៧៧,០៤៨នាក់។ ចេញពីចំនួនសហគមន៍នេះ ៣៥ជាសហគមន៍នេសាទសមុទ្រ។ លើសពីនេះ រដ្ឋបាលជលផលបានបង្កើតបានក្រុមធនាគារក្តាមចំនួន១០ជាមួយនឹងទ្រុងចំនួន២៦។ នៅខេត្តកំពតមានក្រុមធនាគារក្តាម១០ ជាមួយនឹងទ្រុងចំនួន២៥ថែមទៀតត្រូវបានបង្កើតឡើង។ គោលបំណងនៃការបង្កើតក្រុមធនាគារក្តាមនេះ គឺដើម្បីជំរុញឲ្យអ្នកនេសាទប្រមូលក្តាមញីដែលមានពងស្កុកទុកក្នុងទ្រុងដើម្បីធានាដល់ផលិតកម្មក្តាមនាអនាគត ដែលក្នុងពេលជាមួយគ្នានេះក៏ដូចជាដើម្បីការពារជំរកព្រៃកោងកាងដែរ។ ទោះបីជាមានការប្រឹងប្រែងក្នុងការបង្កើតសហគមន៍នេសាទយ៉ាងដូច្នេះក៏ដោយក៏ការខ្វះខាតនៅតែមានដោយសារខ្វះការបង្ហាត់បង្រៀន ត្រួតពិនិត្យ និងសេវាកម្មចែកចាយពត៌មានពីសំណាក់រដ្ឋបាលជលផល និងការគ្រប់គ្រងមិនបានគ្រប់ជ្រុងជ្រោយពីសំណាក់គណៈកម្មការសហគមន៍។

## VII. អនុសាសន៍

បញ្ហាទាក់ទងនឹងការបំផ្លិចបំផ្លាញព្រៃកោងកាងមិនត្រូវបានរដ្ឋាភិបាលកម្ពុជាទាត់ចោលនោះទេ។ គំនិតផ្តួចផ្តើមជាច្រើន ត្រូវបានណែនាំដើម្បីបញ្ឈប់ការបំផ្លាញនេះ:

- ច្បាប់ជលផលដែលបានប្រកាសឲ្យប្រើនៅឆ្នាំ១៩៨៧ បានពិចារណាថា ការទាញយកផលពីព្រៃកោងកាងសម្រាប់គោលបំណងណាមួយ ចាត់ទុកថាខុសច្បាប់។
- សកម្មភាពសិប្បកម្មបង្គារថយចុះជាបន្តបន្ទាប់ដោយសារការបាត់បង់ផលិតភាពនៃបង្គារ ។ ជិត៧០%នៃកសិដ្ឋានចិញ្ចឹមបង្គារត្រូវបានបោះបង់ចោលនៅឆ្នាំ១៩៩៦។ បច្ចុប្បន្ន មានតែមួយចំនួនតូចប៉ុណ្ណោះត្រូវបានគេជឿថាមានសកម្មភាព។

- នៅឆ្នាំ១៩៩៤ រដ្ឋាភិបាលបានបង្កើតអនុក្រឹត្យដើម្បីហាមឃាត់ការកាប់ព្រៃកោងកាងផលិតធ្យូងតាមបណ្តោយតំបន់ឆ្នេរសមុទ្រ។ គណៈកម្មការប្រឆាំងការផលិតធ្យូងត្រូវបានបង្កើតឡើងដែលមានសមាសភាពពីអាជ្ញាធរមូលដ្ឋាន មន្ត្រីក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀតដើម្បីត្រួតពិនិត្យសកម្មភាពផលិតធ្យូងខុសច្បាប់។
- គោលគំនិតថ្មីមួយចំនួនរបស់រដ្ឋាភិបាលទៅលើគម្រោងឆ្នេរសមុទ្រត្រូវបានរៀបរៀងឡើងដែលផ្អែកលើក្រុមការងារដែលតែងតាំងដោយនាយកដ្ឋាននៅប្រចាំខេត្តពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- ជោគជ័យទាំងឡាយត្រូវបានកត់ត្រាជាភស្តុតាង។ ប៉ុន្តែការបំផ្លាញព្រៃកោងកាងនៅតែបន្តមាន។ តទៅខាងមុខទៀត ដើម្បីដោះស្រាយបញ្ហានេះអនុសាសន៍មួយចំនួនដូចខាងក្រោមត្រូវបានលើកឡើង:

១. ដោះស្រាយទំនាស់ឲ្យបានជាបន្ទាន់នៅក្នុងសហគមន៍ និងរវាងសហគមន៍ស្តីអំពីការប្រើប្រាស់តំបន់ឆ្នេរ ជាពិសេសរវាងអ្នកនេសាទទឹករាក់ និងអ្នកនេសាទទឹកជ្រៅ។

២.ធ្វើឲ្យចប់សព្វគ្រប់នូវការកំណត់ព្រំដែននៃព្រៃកោងកាងទាំងអស់ជាមួយនឹងចំនួនផ្ទៃក្រឡាគិតជាហិចតា។

៣. អនុញ្ញាតិ និងជំរុញសហគមន៍មូលដ្ឋាននៅក្នុងការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការបង្កើតសហគមន៍នេសាទឲ្យកាន់តែច្រើន។

៤. ផ្តល់ការបង្ហាត់បង្រៀនបន្ថែម និងជួយជ្រោមជ្រែងដើម្បីជំរុញឲ្យកាន់តែប្រសើរនូវសម្មត្ថភាពនៃក្រុមសហគមន៍នេសាទ និងធ្វើការត្រួតពិនិត្យប្រតិបត្តិការរបស់ពួកគាត់ក្នុងការបង្កើនផលិតកម្មត្រី និងការពារព្រៃកោងកាងទប់ទល់នឹងផលប៉ះពាល់បរិស្ថានអវិជ្ជមាន។

៥. ពង្រឹងការអនុវត្តច្បាប់ និងការដាក់ពិន័យ។

៦. ធ្វើឲ្យកាន់តែប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការរវាងសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អ្នកជំនាញ និងស្ថាប័នពាក់ព័ន្ធទាំងឡាយ ជាពិសេសរដ្ឋបាលជលផល និងក្រសួងបរិស្ថាន។

៧. ដាំដើមកោងកាងឲ្យបានកាន់តែច្រើននៅក្នុងតំបន់ខូចខាត(ដែលអន់ថយ) ក៏ដូចជានៅក្នុងវាលចំហរតាមបណ្តោយតំបន់ឆ្នេរសមុទ្រ។ តាមបណ្តោយឆ្នេរនេះ រដ្ឋបាលជលផល នៅក្នុងគម្រោងផែនការយុទ្ធសាសន៍របស់ខ្លួនសម្រាប់វិស័យជលផលឆ្នាំ២០១០–២០១៩បានដាក់ទិសដៅដាំឈើកោងកាងឲ្យបាន៣០០ហាតនៅឆ្នាំ២០១១ ៧០០ហាតនៅឆ្នាំ២០១៤ និង១០០០ហាតនៅឆ្នាំ២០១៩។ មូលនិធិគ្រប់គ្រាន់គួរត្រូវបានវិភាជន៍សម្រាប់គម្រោងនេះ។

## VIII. សេចក្តីសន្និដ្ឋាន

ប្រជាពលរដ្ឋភាគច្រើនដែលរស់នៅតាមបណ្តោយតំបន់ឆ្នេរសមុទ្រនឹងបន្តពឹងផ្អែកលើការប្រមូលផលិតផលនៅក្នុង និងជុំវិញតំបន់ព្រៃកោងកាងសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់។ សកម្មភាពទាំងនេះនឹងបន្តធ្វើឲ្យព្រៃកោងកាងមានការថយចុះ។ វិធានការការពារ និងដ៏សកម្មទាំងឡាយត្រូវបានចាត់ចែងរួចហើយ ក៏ប៉ុន្តែវិធានការមួយចំនួនទទួលបានជោគជ័យ និងមួយចំនួនទៀតមិនទទួលបានជោគជ័យឡើយ។ ត្រូវបង្កើតកម្មវិធីគ្រប់គ្រងរុក្ខជាតិកោងកាងដ៏មានប្រសិទ្ធភាពមួយ ដោយផ្អែកលើបទពិសោធន៍ដែលធ្លាប់បានជួបពីគណៈកម្មាធិការចម្រុះ ឬគណៈសហាគ្រប់គ្រង (Adaptive Co-Management) នៅស្ទួនឧទ្យានសត្វព្រៃពាមក្រសោប ខេត្តកោះកុង នាពាក់កណ្តាលទសវត្សន៍ឆ្នាំ១៩៩០។ ការគ្រប់គ្រងបែបនេះតម្រូវឲ្យមានការពាក់ព័ន្ធពីសហាគមន៍ ប៉ុន្តែមិនស្ថិតតែក្នុងកម្រិតសហាគមន៍ប៉ុណ្ណោះទេ ការជួយពីរដ្ឋអំណាចខេត្ត និងការគាំទ្រដ៏ទៃទៀតត្រូវតែបូកបញ្ចូលគ្នាក្នុងដំណើរការនេះ។ អ្នកភូមិនឹងបន្តការប្រឹងប្រែងក្នុងដំណើការនៃការគ្រប់គ្រង តែក្នុងករណីមានការគាំទ្រពីសំណាក់រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់។

ការការពារព្រៃកោងកាង មិនមែនតែជាការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋប៉ុណ្ណោះទេ នេះជាភារកិច្ចរួមគ្នានៃអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋក្នុងសហាគមន៍។

ភ្នំពេញ ថ្ងៃទី ខែ សីហា ឆ្នាំ ២០១២

**បណ្ឌិត ស៊ិន ម៉េងស្រ៊ុន**

ប្រធានអនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម

(ក.ស.វ.)